អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖


- គណៈរដ្ឋមន្ត្រីបានអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីអំពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលើកលែងកម្រៃអាជ្ញាប័ណ្ណជើងសាគយដល់វិស័យដឹកជញ្ជូន
- ក្រុមហ៊ុនកសិកម្មទំនើបរបស់ជប៉ុនចាប់ដៃគូជាមួយសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាអភិវឌ្ឍវិស័យកសិកម្ម
- ចុងសប្តាហ៍ទីពីរនៃខែកក្កដា កម្ពុជាទទួលបានភ្ញៀវទេសចរជិត ៧ ម៉ឺននាក់
- ការនាំចេញនាំចូលរបស់ចិនក្នុងពាក់កណ្តាលឆ្នាំនេះទំនងជាមានកំណើនយឺតផ្ទុយពីខែមិថុនា
- ធនាគារកណ្តាលរបស់ថៃបានកែតម្រូវការព្យាករណ៍ ផ.ស.ស
- វៀតណាមនៅតែរំពឹងកំណើន GDP ខ្ពស់នៅឆមាសទី២ ទោះកូវីដ-១៩បន្តរាតត្បាត
- សហភាពអឺរ៉ុប នឹងប្រើប្រាស់ផែនការហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីប្រកួតប្រជែងជាមួយនឹងគម្រោង «ផ្លូវមួយ ខ្សែក្រវ៉ាត់មួយ» របស់រដ្ឋាភិបាលចិន
- សេដ្ឋកិច្ចរុស្ស៊ី ត្រូវបានព្យាករថា នឹងមានកំណើន ៣,៨% នៅឆ្នាំ២០២១



ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## គណៈរដ្ឋមន្ត្រីបានអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីអំពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា




*ប្រភព៖ post Khmer, 2021 រូបភាព៖ SPM*

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានដឹកនាំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តាមរយៈប្រព័ន្ធអនឡាញលើការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី «វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា» ដើម្បីជំនួសច្បាប់ចាស់ដែលកំពុងអនុវត្តជិត២ទសវត្សរ៍កន្លងមកដែលច្បាប់ថ្មីនេះ នឹងដើរតួនាទីសំខាន់ក្នុងការបង្កើននូវកាលានុវត្តភាពថ្មីៗ ដើម្បីស្រូបទាញវិនិយោគិនក្នុង និងក្រៅប្រទេសឱ្យមកបណ្តាក់ទុននៅកម្ពុជាកាន់តែច្រើនឡើង។

សេចក្តីព្រាងច្បាប់ស្តីពី វិនិយោគថ្មីនេះ មាន១២ជំពូក និង ៤២មាត្រា ធ្វើឡើងក្នុងគោលបំណងបង្កើនភាពទាក់ទាញ និងប្រសើរជាងមុននៃការវិនិយោគនៅកម្ពុជា ដោយឈរលើមូលដ្ឋានឯករាជ្យ ម្ចាស់ការ ស្ថានភាពជាក់ស្តែងរបស់វិនិយោគិន និងសេដ្ឋកិច្ច ដែលនឹងបង្កើតក្របខ័ណ្ឌគតិយុត្តដែលមានភាពបើកចំហ មានតម្លាភាព អាចប៉ាន់ប្រមាណទុកជាមុន ក៏ដូចជា ពង្រឹងភាពទាក់ទាញ និងសមត្ថភាពបំពេញបន្ថែម ជាពិសេសបានគិតគូរពីការផ្តល់ការលើកទឹកចិត្តដល់វិស័យអាទិភាព កម្រិតបច្ចេកវិទ្យា និងបច្ចេកទេស ការបង្កើតការងារ ការបណ្តុះ បណ្តាលជំនាញការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និង នវានុវត្តន៍ និងសហគ្រាសធុនតូច និងមធ្យម។

ខ្លឹមសារៈសំខាន់ៗក្នុងសេចក្តីព្រាងច្បាប់នេះ រួមមាន៖ ការបង្កើតរបបលើកទឹកចិត្តវិនិយោគ ការធ្វើទំនើបកម្ម ការបង្កើនផលិតភាពនៃឧស្សាហកម្មក្នុងស្រុក ការពង្រឹងការតភ្ជាប់ទៅខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ និងសកលលោក ការផ្ទេរបច្ចេកវិទ្យា ការបង្កើនភាពប្រកួតប្រជែង ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការផ្តល់ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ ដល់វិនិយោគិននៅកម្ពុជា។ បន្ថែមពីនេះ ក៏មានការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ ការធ្វើប្រតិភូកម្មទៅរដ្ឋបាលរាជធានី-ខេត្ត ការបំព្រួញពេលវេលាក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជី ការកាត់បន្ថយបន្ទុកដល់វិនិយោគិនចំពោះកាតព្វកិច្ចនៃអនុលោមភាពច្បាប់ (ការចុះអធិការកិច្ចរបស់ក្រសួងស្ថាប័ន) ការបង្កើតរបបលើកទឹកចិត្តផ្នែកពន្ធ (ការលើកទឹកចិត្តមូលដ្ឋាន ការលើកទឹកចិត្តបន្ថែម និងលើកទឹកចិត្តពិសេស)។

យោងតាមទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្នុងឆ្នាំ២០១៩ ការអនុម័តគម្រោងវិនិយោគមានទំហំចំនួន ៩,៤ប៊ីលានដុល្លារ ក្នុងនោះប្រទេសចិនមានចំនួន ២,៧ប៊ីលានដុល្លារ ក្រុងហុងកុង ៩១២,៥ លានដុល្លារ និងជប៉ុន ២៩៨,៨ លានដុល្លារ។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១(CDC)បានអនុម័តគម្រោងចំនួន ៧០គម្រោង ក្រោមទុនវិនិយោគសរុប ២ ៤២៨ លានដុល្លារ ក្នុងនោះគម្រោងវិនិយោគវិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរចំនួន២៩គម្រោង ដែលមានទុនវិនិយោគសរុប ១៩៤,៧១ លានដុល្លារ៕

*ដោយ សេន ចន្ទ*

*ប្រភព៖ postkhmer.ចេញផ្សាយថ្ងៃទី១២ខែកក្កដា ឆ្នាំ២០២១*

## រដ្ឋលើកលែងកម្រៃអាជ្ញាប័ណ្ណជើងសាគយ ដល់វិស័យដឹកជញ្ជូន




*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១, រូបភាព៖ ហ៊ីន ពិសី*

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានសម្រេចលើកលែងការបង់កម្រៃអាជ្ញាប័ណ្ណជើងសាគយ សម្រាប់ឆ្នាំ២០២១ និងឆ្នាំ២០២២ ដល់វិស័យដឹកជញ្ជូន និងភស្តុភារកម្មកម្ពុជា ដែលកំពុងតែរងផលប៉ះពាល់ដោយសារវិបត្តិកូវីដ ១៩។

ឯកឧត្តម គុណ ញឹម អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានចេញសេចក្តីសម្រេចលើកលែងការបង់កម្រៃអាជ្ញាប័ណ្ណជើងសាគយ សម្រាប់ឆ្នាំ ២០២១ និង ២០២២ ដើម្បីបន្តជួយវិស័យដឹកជញ្ជូន និងភស្តុភារកម្មកម្ពុជា ដែលកំពុងរងផលប៉ះពាល់ដោយសារការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ បន្ថែមពីនេះ ចំពោះក្រុមហ៊ុនដែលបានបង់កម្រៃជើងសាគយឆ្នាំ២០២១ រួចហើយ នឹងមិនត្រូវបង់កម្រៃអាជ្ញាប័ណ្ណជើងសាគយឆ្នាំ ២០២៣ ទៀតទេ។ សេចក្តីសម្រេចនេះធ្វើឡើងបន្ទាប់ពីការដាក់ចេញវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលក្នុងការបន្តគ្រប់គ្រងផលប៉ះពាល់ដល់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា ក្នុងបរិការណ៍នៃវិបត្តិ និងការស្តារ និងការជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងអំឡុង និងក្រោយវិបត្តិជំងឺកូវីដ ១៩ ជុំទី៩មក ។

យោងតាមលោក ស៊ិន ចន្ធី ប្រធានសមាគមភស្តុភារកម្មកម្ពុជា (CLA) បានលើកឡើងថា សេចក្តីសម្រេចខាងលើនេះ បានជួយសម្រាលបន្ទុកបានមួយផ្នែកដល់វិស័យដឹកជញ្ជូន និងភស្តុភារកម្ម។ ជាក់ស្តែង ការបន្តរីករាលដាលនៃជំងឺកូវីដ១៩ បានធ្វើឱ្យអាជីវកម្មក្នុងវិស័យ នេះធ្លាក់ចុះយ៉ាងខ្លាំង ក្នុងចំណោមអាជីវកម្ម ១២០ក្រុមហ៊ុន គឺមានប្រហែល ១០%ប៉ុណ្ណោះ ដែលអាចទទួលបានចំណូលខ្លះក្នុងការទ្រទ្រង់ដំណើរការប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ចំណែកឯ ៦០% ទៀតពុំទទួលបានប្រាក់ចំណេញទេ និង៣០%ទៀតកំពុងប្រឈមនឹងបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរ ដែលអាចឈានដល់ការផ្អាកអាជីវកម្មជាបណ្តោះអាសន្ន។ គិតមកដល់ពេលនេះ ក្រសួងពាណិជ្ជកម្មបានចុះបញ្ជីអាជ្ញាប័ណ្ណជើងសាគយបានចំនួនប្រមាណ ៥០០ អាជ្ញាប័ណ្ណ។

ទិន្នន័យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករបង្ហាញថាក្នុងត្រីមាសទី១ ឆ្នាំ២០២១ ការប្រមូលចំណូលរបស់ខ្លួនសម្រេចបាន ៦១៤,៨ លានដុល្លារ ធ្លាក់ចុះ ១៥,២% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ លទ្ធផលនៃការប្រមូលចំណូលក្នុងត្រីមាសទី១នេះ សម្រេចបាន ២៦% នៃផែនការប្រចាំឆ្នាំដែលបានគ្រោងទុក៕

*ដោយ មុំ ចិន្តា*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១*

## ក្រុមហ៊ុនកសិកម្មទំនើបរបស់ជប៉ុន ចាប់ដៃគូជាមួយសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា (CACA) អភិវឌ្ឍវិស័យកសិកម្មកម្ពុជាយូរអង្វែង




*ប្រភព ៖ SWIFT NEWS ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១*

ក្រុមហ៊ុនYamato Green Co., Ltd កំពុងចូលរួមអភិវឌ្ឍវិស័យដំណាំបន្លែសុវត្ថិភាពនៅក្នុងផ្ទះសំណាញ់ ដោយប្រើប្រាស់បច្ចេកទេសកសិកម្មទំនើប របស់ជប៉ុន។ ក្រុមហ៊ុននេះ បានចាប់ដៃគូជាមួយសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា (CACA) ក្នុងគោលដៅពង្រឹង និងពង្រីកកិច្ចសហការស៊ីជម្រៅ យូរអង្វែងអភិវឌ្ឍវិស័យកសិកម្មកម្ពុជា។

នៅរសៀលថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ ភាគីទាំង២ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU) ស្តីពី "ភាពជាដៃគូ លើការអភិវឌ្ឍខ្សែសង្វាក់តម្លៃផលិតកម្មបន្លែ" ដែលបានប្រព្រឹត្តទៅនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមអធិបតីឯកឧត្តមរដ្ឋមន្ត្រី និងឯកឧត្តម KARIMATA ATSUHI ឧបទូតនៃស្ថានទូតជប៉ុន រួមនិងថ្នាក់ដឹកនាំពាក់ព័ន្ធមួយចំនួនទៀត។

នៅក្នុងឱកាសនោះ ឯកឧត្តមឧបទូតនៃស្ថានទូតជប៉ុន បានធ្វើចំណាប់អារម្មណ៍អំពីសក្តានុពលវិស័យកសិកម្មកម្ពុជា លក្ខខ័ណ្ឌអំណោយផល បញ្ហាប្រឈម ខ្សែសង្វាក់តម្លៃបន្ថែមនៃបន្លែ និងម្ហូបអាហារ ទីផ្សារ ឱកាសការងារ ប្រាក់ចំណូល ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលបច្ចេកវិទ្យាកសិកម្មជប៉ុនផងដែរ។ ឯកឧត្តមឧបទូតសង្ឃឹម និងជឿជាក់ថា ភាគីហត្ថលេខីនឹងបង្កើនប្រសិទ្ធភាព ក្នុងភាពជាដៃគូអភិវឌ្ឍផលិតកម្មបន្លែនេះបានជោគជ័យ និងជាពិសេសផ្តល់ប្រយោជន៍ដោយត្រង់ដល់ប្រជាកសិករ អ្នកផលិត សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា និងក្រុមហ៊ុន Yamato Green Co., Ltd ។

សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបានបង្កើត និងចុះបញ្ជីផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០។ សម្ព័ន្ធនេះ គឺជានីតិបុគ្គលឯកជន មានលក្ខណៈជាសហគ្រាស សេដ្ឋកិច្ចកសិកម្ម ដែលបានបង្កើតឡើងដោយរូបវន្តបុគ្គល(កសិករ) ចាប់ពី១៥នាក់ឡើងទៅ ហើយអាចប្រកបមុខរបរ រួមមានការធ្វើផលិតកម្មកសិកម្ម កសិ-ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម និងការផ្តល់សេវាកម្មគាំទ្រនានាដល់ផលិតកម្មកសិកម្ម។

បច្ចុប្បន្ននេះមានសហគមន៍កសិកម្មសរុបមានចំនួន ១ ២០០ ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន ១៤៤ ៣០៦នាក់ (ស្ត្រី ៩០ ៦០៣នាក់)។ ភាគហ៊ុនសរុបចំនួន ៤៨ ៣១២ ៣៤៧ ២០០រៀល (ប្រមាណ ១២ លានដុល្លារ) ដែលជាថវិកាផ្ទាល់របស់កសិករដាក់ភាគហ៊ុនវិនិយោគ និងដើមទុនសរុបមានចំនួន ៩៩ ៤៨៩ ៤៨៥ ០៥៩រៀល (ប្រមាណ ២៤,៨ លានដុល្លារ)។ សម្ព័ន្ធបានចុះ MOU ជាមួយក្រុមហ៊ុនឯកជន មីក្រូហិរញ្ញវត្ថុមួយចំនួន និងជាមួយម្ចាស់ជំនួយអន្តរជាតិ

DGRV អាល្លឺម៉ង់។ ក្រៅពីនេះ សម្ព័ន្ធបានជួយសម្របសម្រួលជាមួយ មីក្រូហិរញ្ញវត្ថុក្នុងការផ្តល់ប្រាក់កម្ចីដល់សមាជិកសហគមន៍កសិកម្មផងដែរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១*

## កម្ពុជាទទួលបានភ្ញៀវទេសចរជិត ៧ ម៉ឺននាក់ចុងសប្តាហ៍ទីពីរ នៃខែកក្កដា




*ប្រភព ៖ មន្ទីរទេសចរណ៍រាជធានី ខេត្ត*

ក្នុងថ្ងៃចុងសប្តាហ៍ទីពីរ ខែកក្កដា ឆ្នាំ២០២១ កម្ពុជាទទួលបានភ្ញៀវទេសចរសរុប ៦៩ ៩៣៧នាក់ ក្នុងនោះភ្ញៀវជាតិ ៦៨ ៧៧០ នាក់ និងភ្ញៀវបរទេសផ្ទៃក្នុង ១ ១៦៧ នាក់ នេះបើតាមលោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ចំនួនអ្នកទេសចរតាមគោលដៅទេសចរណ៍សំខាន់ៗ រួមមានដូចខាងក្រោម៖

*រាជធានីភ្នំពេញ៖ ១៩ ៨៦៨នាក់

*ខេត្តកំពត៖ ១០ ០២៤នាក់

*ខេត្តព្រះសីហនុ៖ ៧ ៧១២នាក់

*ខេត្តកំពង់ស្ពឺ៖ ៦ ២៥២នាក់

*ខេត្តបាត់ដំបង៖ ៥ ៥៨៨នាក់

* ខេត្តកណ្តាល៖ ៤ ៤០៩ នាក់។ចំនួននេះមានការថយចុះប្រមាណ ៥,២៣% ធៀបនឹងសប្តាហ៍កន្លងមក និងថយចុះប្រមាណ ៦២,១៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

ការបន្តថយចុះបន្តិចនៃចំនួនភ្ញៀវទេសចរ ធៀបនឹងសប្តាហ៍កន្លងមកនេះ ដោយសារការរឹតបន្តឹងវិធានការរដ្ឋបាលរបស់រាជធានី-ខេត្តមួយចំនួន ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសការផ្អាកសកម្មភាពរមណីយដ្ឋានទេសចរណ៍ និងគោលដៅទេសចរណ៍មួយចំនួន ដែលប្រឈមហានិភ័យនៃការកើនឡើងជំងឺកូវីដ-១៩។

ក្នុងន័យនេះ រដ្ឋបាលរាជធានី-ខេត្ត បានអនុញ្ញាតឱ្យភ្ញៀវ និងប្រជាពលរដ្ឋ ធ្វើដំណើរក្នុងក្រុងធម្មតា លើកលែងតែតំបន់ហាមឃាត់មួយចំនួនតូច ដែលប្រឈមហានិភ័យនៃអត្រាឆ្លងកូវីដ-១៩ខ្ពស់ ប៉ុន្តែគោលដៅទេសចរណ៍តំបន់ឆ្នេរ រួមនឹងគោលដៅអេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិ នៅតែជាគោលដៅសំខាន់សម្រាប់ភ្ញៀវទេសចរផ្ទៃក្នុង។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍ ៖

## តារាងទី១៖ ការប្រៀបធៀបគម្រោងវិនិយោគក្នុងត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០២១

| ឆ្នាំ២០២១ | ចំនួនគម្រោង | ទុនវិនិយោគ (លានដុល្លារ) | បង្កើតការងារថ្មី |
|---|---|---|---|
| មករា | 11 | 44.0 | 7,854 |
| កុម្ភៈ | 10 | 576.5 | 9,154 |
| មីនា | 7 | 58.8 | 4,129 |
| *ត្រីមាសទី១* | *28* | *679.3* | *21,137* |
| មេសា | 6 | 24.4 | 4,724 |
| ឧសភា | 11 | 120.6 | 4,996 |
| មិថុនា | 9 | 116.0 | 7,025 |
| *ត្រីមាសទី២* | *26* | *261.0* | *16,745* |
| ប្រែប្រួលត្រីមាស | -7% | -62% | -21% |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

***សម្គាល់៖*** *ទិន្នន័យនេះពុំមានបូកបញ្ចូលទិន្នន័យរបស់តំបន់សេដ្ឋកិច្ចពិសេសទេ។*

តារាងខាងលើនេះបង្ហាញអំពីចំនួនគម្រោងវិនិយោគឯកជន ក្រៅតំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ក្នុងត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០២១។

វិបត្តិនៃការរីករាលដាលនៃជំងឺឆ្លងកូវីដ១៩ បានធ្វើឱ្យស្ថានភាពវិនិយោគរបស់កម្ពុជា មិនទាន់មានភាពល្អប្រសើរនៅឡើយទេ។ ជាក់ស្តែងក្នុងត្រីមាសទី២ ឆ្នាំ២០២១ គម្រោងវិនិយោគឯកជនសរុបមានចំនួន ២៦ គម្រោង ធ្លាក់ចុះ ៧% ខណៈទុនវិនិយោគមានចំនួន ២៦១លានដុល្លារ បានធ្លាក់ចុះ ៦២% ហើយគម្រោងទាំងនេះអាចមានលទ្ធភាពបង្កើតការងារថ្មីប្រមាណជា ១៦ ៧៤៥នាក់ បានធ្លាក់ចុះ ២១% បើធៀបនឹងត្រីមាសទី១។

គម្រោងដែលបានអនុញ្ញាតដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ភាគច្រើនគឺគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ កាបូបធ្វើដំណើរ ស្បែកជើង សម្ភារអេឡិច-ត្រូនិច និងគម្រោងបង្កើតថាមពលអគ្គិសនីដោយពន្លឺព្រះអាទិត្យ។ *ដោយ មុំ ចិន្តា*

## តារាងទី២ ៖ ចំណែកទីផ្សារអន្តរជាតិ សម្រាប់ទំនិញនាំចេញកម្ពុជា ក្នុងរយៈពេល៥ខែ ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា ក្នុងរយៈពេល៥ខែឆ្នាំ២០២១ ការនាំចេញទំនិញកម្ពុជាទៅកាន់ទីផ្សារ អាមេរិកមានចំណែកទីផ្សារដល់ ៣៩,៥% នៃការនាំចេញសរុប និងតាមពីក្រោយដោយសហគមន៍អឺរ៉ុប ដែលមានចំណែកទីផ្សារប្រមាណជា ១៨,៨%នៃការនាំចេញសរុបរបស់កម្ពុជា។

ចំណែកការនាំចេញទំនិញកម្ពុជាទៅកាន់ប្រទេសសចិន មានចំណែកទីផ្សារប្រមាណជា ៩,៣% ជប៉ុនមាន៧% អង់គ្លេសមាន៤% និងបណ្តាប្រទេសអាស៊ានមានចំណែកទីផ្សារប្រមាណជា០,៨%។ ដោយឡែក

ការនាំចេញទៅកាន់បណ្តាប្រទេសផ្សេងៗ មានចំណែកទីផ្សារនាំចេញរហូតដល់ ១៣,២% នៃការនាំចេញសរុប៕

*ដោយ មិត្ត ចន្ធី*




ប្រភព៖និន្នាការសេដ្ឋកិច្ចសង្គម៖ របាយការណ៍ប្រចាំខែឧសភា ឆ្នាំ២០២១




ប្រភព៖និន្នាការសេដ្ឋកិច្ចសង្គម៖ របាយការណ៍ប្រចាំខែឧសភា ឆ្នាំ២០២១

## តារាងទី៣ ៖ កំណើននៃការនាំចេញទំនិញ រយៈពេល៥ខែដំបូង ក្នុងឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា នៅក្នុងរយៈពេល៥ខែដំបូងឆ្នាំ២០២១នេះ ការនាំចេញទំនិញវាយនភ័ណ្ឌ មានការធ្លាក់ចុះប្រមាណជា ០,៦% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ទន្ទឹមនឹងនោះដែរ ការនាំចេញអង្ករក៏មានការធ្លាក់ចុះប្រមាណជា ២៩,៨%ផងដែរ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។ ក៏ប៉ុន្តែ នៅក្នុងរយៈពេល៥ខែឆ្នាំ២០២១នេះ ការនាំចេញកង់មានកំណើនប្រមាណជា ៣១,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន។

ស្របពេលនោះដែរ ការនាំចេញទំនិញផ្សេងៗ ក៏មានកំណើនប្រមាណជា ៧,៤% ធៀបនឹងរយៈពេល៥ខែដំបូងដូចគ្នាកាលពីឆ្នាំមុន ។ *ដោយ៖ មិត្ត ចន្ទី*

# ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ការនាំចេញនាំចូលរបស់ចិនក្នុងត្រីមាសទី២ នៃឆ្នាំនេះ ទំនងជាមានកំណើនយឺត ផ្ទុយពីខែមិថុនា



*កាលពីខែមិថុនាការនាំចេញរបស់ចិនមានកំណើន ៣២,២% ធៀបទៅនឹងដើមឆ្នាំ ខណៈដែលការនាំចូលមានកំណើន ៣៦,៧%។រូបថតដោយ៖ AP*

កំណើនពាណិជ្ជកម្មរបស់ចិនទាំងការនាំចេញ និងការនាំចូល អាចនឹងមានកំណើនយឺតនៅឆមាសទី២ នៃឆ្នាំនេះ ខណៈដែលកំណើនពេញមួយឆ្នាំត្រូវបានរំពឹងទុកថានឹងអាចរក្សាកំណើនបានខ្ពស់។ កាលពីខែមិថុនា កំណើនពាណិជ្ជកម្មរបស់ចិន កើនឡើងខ្ពស់ជាងការរំពឹងទុក ដែលបានកើនឡើងពី ៣២,២% ក្នុង ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ស្មើនឹង ២៨១,៤២ប៊ីលានដុល្លារ (កើនពីកំណើន ២៧,៩%នៅក្នុងខែឧសភា) ចំណែកឯការនាំចូល ក៏មានការកើនឡើង ៣៦,៧% ក្នុងខែមិថុនា នេះបើធៀបទៅនឹងការនាំចូលខែមិថុនាកាលពីឆ្នាំមុន ស្មើនឹង ២២៩,៨៩ប៊ីលានដុល្លារ ដែលធ្លាក់ចុះពីកំណើន៥១,១%នៅក្នុងខែឧសភា ។

រីឯតុល្យភាពពាណិជ្ជកម្មរវាងចិន ជាមួយសហរដ្ឋអាមេរិកនៅក្នុងខែមិថុនាមានអតិរេកដល់ទៅ ៣២,៥៨ប៊ីលានដុល្លារ ដោយសារតែការនាំចូលរបស់ចិនពីសហរដ្ឋអាមេរិកកាលពីខែមិថុនាកើនឡើង៣៧,៥៥% ស្មើនឹង ១៤,៣៣ប៊ីលានដុល្លារ ខណៈដែលការនាំចេញទៅសហរដ្ឋអាមេរិក មានកំណើន១៧,៧៨% ស្មើនឹង ៤៦,៩១ប៊ីលាន។ គួរបញ្ជាក់ផងដែរថាកាលពីខែមិថុនា តុល្យភាពពាណិជ្ជកម្មរវាងចិន ជាមួយសហគមន៍អឺរ៉ុបមានអតិរេកចំនួន ១៥,៣៦ប៊ីលានដុល្លារ កើនឡើង ១៦,៣៧% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ដោយឡែក ការនាំចេញរបស់ចិនទៅប្រទេសអូស្ត្រាលីពីខែមិថុនាកើន ២៧,៦៩% ស្មើនឹង ៥,៤៨ប៊ីលានដុល្លារ ខណៈដែលការនាំចូលកើន ៥៣,៥១% ស្មើនឹង ១៤,៦៧ប៊ីលានដុល្លារ នាំឱ្យ តុល្យភាពពាណិជ្ជកម្មរវាងចិន និងប្រទេសអូស្ត្រាលីមានឱនភាពពាណិជ្ជកម្មចំនួន ៩,១៩ប៊ីលានដុល្លារ កើនឡើង ៧៤,៥៤% ធៀបនឹងខែដូចគ្នាធៀបនឹងឆ្នាំមុន។ ចំណែកការនាំចេញរបស់ចិនទៅអាស៊ានកាលពីខែមិថុនាកើនឡើង ៣៣,១៤%ស្មើនឹង៤០,៣៦ ប៊ីលានដុល្លារ។ រីឯការនាំចូលពីអាស៊ាន កើនឡើង ៣៣,៦៩% ស្មើនឹង ៣៣,៧៤ប៊ីលានដុល្លារ នាំឱ្យតុល្យភាពពាណិជ្ជកម្មរវាងចិន និងអាស៊ានមានអតិរេកចំនួន ៦,៦៣ប៊ីលានដុល្លារ កើន៣០,៤២% ធៀបនឹងខែមិថុនាឆ្នាំមុន ដែលនាំឱ្យអាស៊ាន ក្លាយជាដៃគូពាណិជ្ជកម្មដ៏ធំរបស់ចិន តាមពីក្រោយដោយសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក។

គួររម្លឹកផងដែរថា ការនាំចេញរបស់ចិននៅក្នុងឆមាសទី១ ឆ្នាំ២០២១ កើនឡើង៣៨,៦% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន មានទំហំស្មើនឹង១,៥២ទ្រីលានដុល្លារ ខណៈដែលការនាំចូលសរុប នៅក្នុងឆមាសទី១ឆ្នាំ២០២១ មានកំណើន ៣៦,០% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនស្មើនឹង ១,២៧ទ្រីលានដុល្លារ ដែលជាហេតុនាំឱ្យតុល្យភាពពាណិជ្ជកម្មរបស់ចិនសរុបមាន អតិរេកចំនួន ២៥១,៥២ប៊ីលានដុល្លារ។ ទំនិញនាំចូលរបស់ចិនរួមមាន៖ ដែក ចំនួន ៥៦១លានតោន កើនឡើង២,៦% ពោត ១៥,៣០លានតោន កើនបាន ៣១៨,៥% ស្រូវសាលី ៥,៣៦លានតោន កើនដល់ទៅ ៦០,១% និងសណ្តែកសៀងមានចំនួន ៤៨,៩៦លានតោន កើនឡើងចំនួន ៨,៧%។ ប៉ុន្តែទន្ទឹមនឹងនេះ ការនាំចូលប្រេងឆៅបែរជាធ្លាក់ចុះចំនួន ៣% ស្មើនឹង ២៦១ លានតោន ខណៈការនាំចូលឧស្ម័នធម្មជាតិកើនឡើង ២៣,៨% ស្មើនឹង ៥៩,៨១៩លានតោន៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ South China Moring Post ចេញផ្សាយថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០២១*

## ធនាគារកណ្ដាលរបស់ថៃ បានកែតម្រូវការព្យាករណ៍ ផ.ស.ស



*ប្រជាជនថៃកំពុងចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩នៅមហោស្រព កណ្ដាល Eastville ថតដោយ៖ Varuth Hirunyatheb*

ធនាគារកណ្ដាលរបស់ថៃបានព្យាករណ៍ថា វិធានការបិទខ្ទប់ ដែលរដ្ឋាភិបាលបានដាក់ចេញចុងក្រោយនេះ អាចនឹងធ្វើឱ្យសេដ្ឋកិច្ចរបស់ថៃធ្លាក់ចុះយ៉ាងខ្លាំង ដោយសារតែការឆ្លងរីករាលដាលកូវីដ១៩ បំប្លែងខ្លួនថ្មីឈ្មោះថា Delta។ យោងតាមការព្យាករណ៍សេដ្ឋកិច្ច ដោយផ្អែកលើសេណារីយ៉ូដើមគ្រាដែលបានធ្វើឡើង ដោយធនាគារកណ្ដាល និងត្រូវបានរាយការណ៍កាលពីថ្ងៃទី២២ ខែមិថុនាកន្លងទៅ នឹងត្រូវបានពិនិត្យឡើងវិញ ដោយសារការបន្តការរីករាលដាលនៃជំងឺកូវីដ១៩ ពោលគឺ ធនាគារកណ្ដាលបានធ្វើការព្យាករណ៍ដោយកាត់បន្ថយកំណើនសេដ្ឋកិច្ចរបស់ថៃក្នុងឆ្នាំ២០២១ ពី ៣% មកនៅត្រឹម១,៨%ដោយសារតែសេដ្ឋកិច្ចរបស់ថៃទទួលរងផលប៉ះពាល់ពីកូវីដ១៩ រលកទីបី។
ប៉ុន្តែកំណើននេះ នឹងត្រូវធ្វើការកែប្រែជាបន្តទៀត។ ធនាគារកណ្ដាល នឹងធ្វើការឃ្លាំមើលស្ថានភាពលើទិដ្ឋភាពជាក់ស្ដែងនៃការឆ្លងរីករាលដាលជំងឺកូវីដបំប្លែងខ្លួនថ្មី Delta អំពីចំនួនអ្នកឆ្លង និងវិធានការរបស់រដ្ឋាភិបាលដូចជា៖ ការឧបត្ថម្ភកធន និងការរឹតបន្តឹងលើវិធានការផ្សេងៗទៀត ព្រោះចំនួននៃការឆ្លងរីករាលដាលនេះនឹងធ្វើឱ្យការបិទខ្ទប់មានការពន្យាពេល និងនាំឱ្យការស្ដារសេដ្ឋកិច្ចឡើងវិញមានភាពយឺតយ៉ាវ។

កន្លងមករដ្ឋាភិបាលថៃ បានចាត់វិធានការជួយទ្រទ្រង់ដល់សហគ្រាសធុនតូច និងមធ្យម (SMEs) តាមរយៈការផ្ដល់ប្រាក់កម្ចី។ ជាក់ស្ដែងកាលពីថ្ងៃទី៥ ខែកក្កដា រាជរដ្ឋាភិបាល បានអនុម័តទឹកប្រាក់កម្ចីចំនួន៦៦,៨៩ ប៊ីលានលានបាត ក្នុងនោះទឹកប្រាក់ចំនួន៣,១លានបាត ត្រូវបានប្រើប្រាស់ សម្រាប់ជួយដល់សហគ្រាសចំនួន ២១ ៩២៩។
នាយកប្រតិបត្តិជាន់ខ្ពស់នៃនាយកដ្ឋានគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ រំពឹងថា បន្ទាប់ពីការអនុវត្តប្រាក់កម្ចីតាំងពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ រដ្ឋាភិបាល អាចនឹងផ្ដល់ប្រាក់កម្ចីរហូតដល់ ១០០ប៊ីលានបាត ដើម្បីជួយទ្រទ្រង់ដល់សហគ្រាស ដែលកំពុងរងគ្រោះដោយសារតែវិបត្តិកូវីដ១៩ ក្នុងអំលុងពេលប្រាំមួយខែដំបូងនេះ។ ទន្ទឹមនឹងនេះកញ្ចប់ជំនួយផ្នែកហិរញ្ញវត្ថុមួយទៀតក៏គ្រោងនឹងបង្កើតឡើងផងដែរ ដែលមានទឹកប្រាក់ប្រមាណជា ១០ប៊ីលានបាត។

បច្ចុប្បន្ននេះ មានប្រតិបត្តិការអាជីវកម្មចំនួនពីរដែលបានផ្ដល់ឥណទានសរុបចំនួន ៩០០លានបាត ដើម្បីទ្រទ្រង់ដល់គ្រោងការហិរញ្ញប្បទានថ្មីនេះ។ បន្ថែមពីនោះ ធនាគារជាតិរបស់ថៃកំពុងតែពិចារណាកាត់បន្ថយអត្រាការប្រាក់សម្រាប់កម្ចីដែលពុំមានសុវត្ថិភាព ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់រដ្ឋាភិបាល ដើម្បីបន្ធូរបន្ថយលក្ខខណ្ឌចំពោះអ្នកខ្ចីប្រាក់ដើម្បីទប់ទល់បំណុលនៅក្នុងគ្រួសារនីមួយៗ៕

*ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ គេហទំព័រ Bankork Post ចេញផ្សាយថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០២១ និងបានធ្វើបច្ចុប្បន្នភាពថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១*

## វៀតណាមនៅតែរំពឹងកំណើន GDP ខ្ពស់នៅឆមាសទី២ ទោះបីជំងឺកូវីដ-១៩ បន្តរាតត្បាត



*ប្រភព៖ cambonomist, ២០២១*

រដ្ឋាភិបាលវៀតណាម បានព្យាករពីកំណើន ផលិតផលក្នុងស្រុកសរុប ឬGDP នៅឆមាសទី២ ឆ្នាំ២០២១នេះ ថា អាចនឹងសម្រេចបានចន្លោះពី៦ ទៅ៦,៥%។

កំណើន GDP របស់វៀតណាម នៅឆមាសទី១ ឆ្នាំ ២០២១ សម្រេចបាន៥,៦% ហើយនៅឆមាសទី២នេះ ត្រូវបានព្យាករថានឹងកើនបន្ថែមទៀត ប៉ុន្តែហាក់កំពុងស្ថិតក្នុងភាពស្រពេចស្រពិលនៅឡើយ ព្រោះស្ថានភាពកូវីដ-១៩ នៅវៀតណាមនៅរយៈពេលចុងក្រោយនេះ មានការហក់ឡើងខ្ពស់។

បើតាមការអះអាងរបស់មន្ត្រីជាន់ខ្ពស់នៃក្រសួងផែនការ និងវិនិយោគវៀតណាម នៅក្នុងសេណារីយ៉ូទី១ សេដ្ឋកិច្ចវៀតណាមអាចនឹងកើន ៦% ប្រសិនបើស្ថានភាពរលកឆ្លងកូវីដ-១៩ ត្រូវបានគ្រប់គ្រងបាន នៅក្នុងខែកក្កដា ហើយមិនមានការផ្ទុះរាលដាលទ្រង់ទ្រាយធំថ្មីទៀតនៅក្នុងទីតាំងឧស្សាហកម្ម និងទីក្រុងធំៗ។

មន្ត្រីជាន់ខ្ពស់វៀតណាមរូបនេះបន្ថែមទៀតថា សម្រាប់សេណារីយ៉ូទី២ សេដ្ឋកិច្ចវៀតណាម អាចនឹងកើនដល់ ៦,៥% ប្រសិនបើរលកឆ្លងកូវីដ-១៩ អាចគ្រប់គ្រងបាននៅក្នុងខែមិថុនា ប៉ុន្តែមានការប្រឈមច្រើនណាស់ចំពោះគោលដៅនេះ ព្រោះស្ថានភាពឆ្លងរាលដាលកូវីដ-១៩ នៅតែមានភាពស្មុគស្មាញ។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cambonomist*

## សេដ្ឋកិច្ចសកល

### សហភាពអឺរ៉ុប នឹងប្រើប្រាស់ផែនការហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីប្រកួតប្រជែងជាមួយនឹងគម្រោង « ផ្លូវមួយ ខ្សែក្រវ៉ាត់មួយ» របស់រដ្ឋាភិបាលចិន



*ប្រភព៖ Reuters ២០២១ រូបភាព៖ Jason Lee*

នៅថ្ងៃទី១២ ខែកក្កដា សហភាពអឺរ៉ុប បានសម្រេចដាក់ដំណើរការជាផ្លូវការ នូវផែនការហេដ្ឋារចនាសម្ព័ន្ធសកលរបស់ខ្លួន ក្នុងការតភ្ជាប់តំបន់អឺរ៉ុបទៅនឹងពិភពលោក និងជាពិសេស បន្ទាប់ពីបានចុះកិច្ចព្រមព្រៀង ពាណិជ្ជកម្មនាពេលថ្មីៗនេះ ជាមួយប្រទេសជប៉ុន និងឥណ្ឌា។

ជាការពិតណាស់ សហភាពអឺរ៉ុបមានការសង្ស័យទៅលើគម្រោងផ្តួចផ្តើម «ផ្លូវមួយ ខ្សែក្រវ៉ាត់មួយ» របស់ចិន ដែលបានធ្វើឡើង ក្នុងគោលបំណងដោះដូរយកឥទ្ធិពលនយោបាយនៅទូទាំងពិភពលោក ហេតុដូចនេះ សហ

ភាពអឺរ៉ុប សម្រេចដាក់អនុវត្តនូវផែនការការតភ្ជាប់របស់ខ្លួន ដើម្បីផ្ដល់ជាជម្រើសផ្សេងមួយទៀត ទៅដល់ពិភពលោក។

ជាក់ស្ដែង កិច្ចព្រមព្រៀងជាដៃគូពាណិជ្ជកម្មរវាងសហភាពអឺរ៉ុប ជាមួយនឹងប្រទេសឥណ្ឌា និងជប៉ុន ក៏បានតភ្ជាប់អឺរ៉ុប ទៅនឹងអាស៊ីដែរ។ ទន្ទឹមនេះដែរ រដ្ឋាភិបាលជប៉ុន និងឥណ្ឌា សុទ្ធតែមានការព្រួយបារម្ភលើជំនួយសប្បុរសធម៌របស់ចិន ដែលបណ្ដាលឱ្យប្រទេសក្រីក្រ មានកាតព្វកិច្ចក្នុងការសងគុណទៅកាន់ប្រទេសចិនវិញ។ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលចិន បានឆ្លើយតបថា គម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន គឺផ្ដោតលើតម្រូវការរបស់ប្រជាជនធម្មតាប៉ុណ្ណោះ និងមិនមានគោលបំណងក្នុងការបង្ហាញអំណាចនោះឡើយ។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១*

## សេដ្ឋកិច្ចរុស្ស៊ី ត្រូវបានព្យាករថា នឹងមានកំណើន ៣,៨% នៅឆ្នាំ២០២១




*ប្រភព៖ BNE Intellinews ២០២១, រូបភាព៖ Rosstat, ក្រសួងអភិវឌ្ឍសេដ្ឋកិច្ចរុស្ស៊ី*

អ្នកនាំពាក្យរបស់ក្រសួងអភិវឌ្ឍសេដ្ឋកិច្ចរុស្ស៊ី បានលើកឡើង កាលពីថ្ងៃទី៩ ខែកក្កដានេះថា សេដ្ឋកិច្ចរុស្ស៊ី ក្នុងឆ្នាំ២០២១នេះ នឹងអាចមានកំណើនដល់ទៅ ៣,៨% ដែលខ្ពស់ជាងការរំពឹងទុកកាលពីលើកមុន ដែលមានត្រឹមតែ ២,៩%។ ការណ៍នេះបណ្ដាលមកពីស្ថានភាពដ៏ល្អប្រសើរនៃតម្រូវការអ្នកប្រើប្រាស់ ក៏ដូចជា ការវិនិយោគ។ ដោយឡែក ចំពោះការព្យាករ ឆ្នាំ២០២២ និងឆ្នាំ២០២៣-២០២៤ ត្រូវបានរក្សាដូចការព្យាករលើកមុន ក្នុងអត្រា ៣,២% និង ៣,០%រៀងគ្នា។

គួរបញ្ជាក់ថា នៅឆ្នាំ២០២០ សេដ្ឋកិច្ចរុស្ស៊ី បានធ្លាក់ចូលទៅក្នុងវិបត្តិ ជាមួយនឹងកំណើនអវិជ្ជមាន ៣% ក៏ប៉ុន្តែ បានងើបឡើងវិញ នៅត្រីមាសទី១ នៅឆ្នាំនេះ និងមានភាពរឹងមាំជាងការរំពឹងទុក។ បន្ថែមពីនេះ សេដ្ឋកិច្ចក៏នឹងអាចវិលត្រលប់ទៅរកកម្រិតមុនវិបត្តិវិញ នៅខែកក្កដានេះ។

បើក្រឡេកមើលអត្រាគ្មានការងារធ្វើវិញ ឃើញថា មានការធ្លាក់ចុះមកនៅត្រឹម ៤,៩% នៅខែឧសភា រីឯអត្រាអតិផរណា មានការកើនឡើងទៅអត្រា ៦,៥% ហើយអាចនឹងបន្តខ្ពស់ជាងនេះទៀត ដែលនៅតែជាបញ្ហាចម្បងមួយ។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ BNE Intellinews ចេញផ្សាយ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្ដាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១៩ ខែកក្កដា ឆ្នាំ២០២១

- កំណើនទំនុកចិត្តអ្នកប្រើប្រាស់របស់ប្រទេសទួរគីបានកើនក្នុងកម្រិតខ្ពស់បំផុតចាប់តាំងពីខែមីនា និងខែមិថុនាឆ្នាំ ២០២១
- ការប្រកាសដំឡើងអត្រាការប្រាក់លើកទី៣នៃធនាគារកណ្ដាលប្រេស៊ីលនៅឆ្នាំ២០២១ ដើម្បីកាត់បន្ថយ អតិផរណា
- សន្ទស្សន៍ទីផ្សារលំនៅដ្ឋាននៅសហរដ្ឋអាមេរិកបានធ្លាក់ចុះ ក្នុងខែនីមួយៗនៃពីរខែមុនដែលទាបជាងការព្យាករណ៍

ថ្ងៃអង្គារ ទី២០ ខែកក្កដា ឆ្នាំ២០២១

- តម្លៃទំនិញប្រើប្រាស់របស់ប្រទេសជប៉ុនបាន ធ្លាក់ចុះ ០,១ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំក្នុង ខែឧសភាឆ្នាំ២០២១ បន្ទាប់ពីការធ្លាក់ចុះ ០,៤ ភាគរយកាលពីខែមុន
- អតិរេកគណនីចរន្តនៅតំបន់ចាយប្រាក់អឺរ៉ូបាន កើនឡើងយ៉ាងខ្លាំង ក្នុងខែមេសាឆ្នាំ ២០២១
- កំណើនការលក់រថយន្តនៅប្រទេសឥណ្ឌូនេស៊ី បាន ពីមួយឆ្នាំទៅមួយឆ្នាំ ដែលមិនធ្លាប់មាន

ថ្ងៃពុធ ទី២១ ខែកក្កដា ឆ្នាំ២០២១

- កំណើនផលិតផលក្នុងស្រុកសរុបរបស់សហព័ន្ធ រុស្ស៊ី ក្នុងរយៈពេល ៥ ខែដំបូងនៃឆ្នាំ ២០២១
- កំណើននៃការលក់រាយនៅអូស្ត្រាលី បានកើន ឡើង ០,៤ ភាគរយពីមួយខែទៅមួយខែក្នុងខែ មិថុនាឆ្នាំ ២០២១

ថ្ងៃព្រហស្បតិ៍ ទី២២ ខែកក្កដា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអាហ្សង់ទីន បានរួមតូច ក្នុងខែឧសភាឆ្នាំ ២០២១
- ការថយចុះនៃតម្លៃប្រាក់កម្ចីនៅក្នុងប្រទេស ឥណ្ឌូនេស៊ី នៅក្នុងខែឧសភាឆ្នាំ ២០២១
- កំណើននៃស្តុកឧស្ម័ននៅក្នុងឃ្លាំង សហរដ្ឋអា មេរិកបានកើនឡើង១៦ ពាន់លានហ្វីតគូបក្នុង ខែកក្កដាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី២៣ ខែកក្កដា ឆ្នាំ២០២១

- ការលក់រាយនៅចក្រភពអង់គ្លេស បានធ្លាក់ចុះ ក្នុងខែឧសភាឆ្នាំ ២០២១
- ធនាគារកណ្តាលនៃប្រទេសរុស្ស៊ី បានដំឡើង អត្រាគោលគោលរបស់ខ្លួនដោយ អតិផរណា កំពុងកើនលើសគោលដៅរបស់ធនាគារ។
- ទំនុកចិត្តអាជីវកម្មនៅប្រទេសរុស្ស៊ីបានធ្លាក់ចុះ ដល់ ០ ពិន្ទុក្នុងខែមិថុនាពី ០.៣០ ពិន្ទុនៅខែ ឧសភាឆ្នាំ ២០២១៕